云南日报
YUNNAN DAILY PRESS GROUP
云南日报报业集团
No.121

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

YUNNAN DAILY
PRESS GROUP
english.yunnan.cn

ឆ្នាំទី 25 លេខ 7411 ថ្ងៃសុក្រ ទី 18 ខែ សីហា ឆ្នាំ 2017

## ឡានក្រុងដែលជាជំនួយរបស់ប្រទេសចិន ត្រូវដាក់ឱ្យប្រើប្រាស់នៅក្នុងរាជធានីភ្នំពេញ

***ដោយ យូ ជាំងនីង និង ទឹង ហ៊ីង***

ប៉ុន្មានថ្ងៃនេះ ឡានក្រុងថ្មីច្រើនដែលដាក់អក្សរ "ជំនួយចិន" បានត្រូវដាក់ឱ្យប្រើប្រាស់នៅក្នុងរាជធានី-ភ្នំពេញ ។ ឡានក្រុងទាំងនេះផលិតដោយ ក្រុមហ៊ុន ផលិតរថយន្តយូធុងក្រុងជឹងចូវប្រទេសចិនសរុបមាន ១០០គ្រឿង ។ តាមប្រភពព័ត៌មានបានឱ្យដឹងថា ឡានក្រុងថ្មីទាំងនេះបានត្រូវបំពាក់ដោយ ប្រព័ន្ធបញ្ជាដែលមានលក្ខណៈវៃឆ្លាត តាមស្ថានភាពជាក់ស្តែងនៃប្រទេសកម្ពុជាដើម្បីបំពេញតម្រូវការពិសេស របស់ប្រទេសកម្ពុជា ។ ជាពិសេសក្រុមហ៊ុនបានរៀបចំការបណ្តុះបណ្តាលចំពោះតៃកុង និងអ្នកបច្ចេកទេស ជនជាតិខ្មែរ ។

ប៉ុន្មានឆ្នាំនេះ រាជធានីភ្នំពេញបានទទួលការរីកចម្រើនច្រើនគួរឱ្យកត់សម្គាល់ ដោយមានទំហំកាន់តែធំ និងប្រជាជនកាន់តែច្រើន ។ ដូច្នេះប្រព័ន្ធគមនាគមន៍សាធារណៈបាននិងកំពុងដើរតួនាទីកាន់តែសំខាន់ឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ។ ក្នុងគោលបំណងបង្កើតប្រព័ន្ធគមនាគមន៍សាធារណៈដែលមានលក្ខណៈកាន់តែល្អប្រសើរ



អ្នកដំណើរកំពុងតែរង់ចាំឡានក្រុង (រូបថតដោយ Yu Jiangning )

កែលម្អល័ក្ខខ័ណ្ឌសម្រាប់ការធ្វើដំណើររបស់អ្នកក្រុង ផ្តល់ការងាយស្រួល និងផលប្រយោជន៍កាន់តែច្រើនដល់ប្រជាជន សាលាក្រុងភ្នំពេញសម្រេចយកឡានក្រុងដែលជាជំនួយរបស់រដ្ឋាភិបាលចិននោះមកជំនួសឡានក្រុងចាស់៥៧គ្រឿង ដែលកំពុងតែប្រើប្រាស់សម្រាប់ខ្សែឡានក្រុង៣ខ្សែក្នុងទីក្រុងភ្នំពេញ ។ ទន្ទឹមនឹងនេះ សាលាក្រុងភ្នំពេញមានផែនការបង្កើតខ្សែឡានក្រុងថ្មីចំនួន៥ទៀតក្នុងពេលឆាប់ៗ ។ កាលនោះក្រុងភ្នំពេញនឹងអាចមានឡាន-ក្រុង៨ខ្សែសម្រាប់បំពេញតម្រូវការនៃការធ្វើដំណើរទៅមករបស់អ្នកក្រុង ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅ ប្រទេសកម្ពុជា និងចិនតែងតែជួយគ្នាទៅវិញទៅមក ដើម្បីជំរុញការអភិវឌ្ឍបុព្វហេតុកសាងប្រទេស និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន ហើយបានទទួលសមិទ្ធផលច្រើន និងបានផ្តល់ផលប្រយោជន៍ច្រើនដល់ប្រជាជននៃប្រទេសទាំងពីរចិននិងកម្ពុជា ៕

## គ្រូពេទ្យចិនមួយរូបដែលសង្គ្រោះជីវិតគេនៅប្រទេសកម្ពុជា

***ដោយ ហួង យ៉ាវហុយ (ទីភ្នាក់ងារព័ត៌មានចិន)***

បុរសខ្មែរម្នាក់ឈ្មោះ "អាលី" បានប្រាប់អ្នកកាសែត ដោយប្រើប្រាស់ភាសាចិនថា លោកប្រធានឆឹន ដែលមកពីមន្ទីរពេទ្យហុនអិនមានបច្ចេកទេសខ្ពស់ក្នុងការព្យាបាលជំងឺ ហើយយកថ្លៃមិនខ្ពស់ទេ ដូច្នេះគេចូលចិត្តទៅរកលោកប្រធានឆឹន ជួយព្យាបាលជំងឺ ។

គ្រូពេទ្យដែលត្រូវអាលីហៅ "ប្រធានឆឹន" នោះ គឺលោកឆឹន ស៊ីនហួ ។ លោកជាគ្រូពេទ្យចិនមួយរូប ដែលបានបង្កើតមន្ទីរពេទ្យចិនទី១ នៅប្រទេសកម្ពុជា ។ មិនតែប៉ុណ្ណោះ លោកជាអនុ-ប្រធានសភាពាណិជ្ជកម្មចិននៅកម្ពុជា ហើយក៏ជាប្រធានសភាពាណិជ្ជកម្មខេត្តហឺប៉េ ប្រចាំនៅប្រទេសកម្ពុជាដែរ ។

នៅខែកុម្ភៈ ឆ្នាំ ១៩៩៧ លោកឆឹន ស៊ីនហួ អមដំណើរលោកអនុប្រធានមន្ទីរពេទ្យប្រជាជនទី៥ ខេត្តហឺប៉េ ទៅបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជា ហើយបានផុសគំនិតចង់បង្កើតមន្ទីរ-ពេទ្យចិនមួយនៅប្រទេសកម្ពុជា ព្រមទាំងនាំយកគ្រឿងបរិក្ខារសុខាភិបាលមួយចំនួនទៅប្រទេសកម្ពុជា ។

លោកបានបញ្ជាក់ថា កាលនោះកម្ពុជាខ្វះគ្រូពេទ្យ និងថ្នាំ ដូច្នេះមន្ទីរពេទ្យរបស់លោកបានសម្រេចចាត់បញ្ជូនលោកឱ្យទៅប្រទេសកម្ពុជា ។ ក្រោមកិច្ចខិតខំរបស់លោកមន្ទីរពេហុ-ព្យាបាលផេប៉ូឡុងដែលជាមន្ទីរពេទ្យចិនទី១ទទួលស្គាល់ដោយរដ្ឋាភិបាលចិន និង កម្ពុជា បានត្រូវបង្កើតនៅឆ្នាំ ១៩៩៩ ក្នុងរាជធានីភ្នំពេញ ។ លោកបានធ្វើជាប្រធាននៃមន្ទីរពេទ្យនេះ ។

ប៉ុន្តែកាលនោះ រាជរដ្ឋាភិបាលកម្ពុជានៅមិនទាន់ទទួលស្គាល់លក្ខណ-សម្បត្តិរបស់គ្រូពេទ្យចិនទេ។ ប៉ុន្តែលោកបានទាក់ទងជាមួយក្រសួងសុខាភិបាលកម្ពុជាជាច្រើនលើកច្រើនសាហើយបានធ្វើឱ្យស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋា-ភិបាលកម្ពុជាទទួលស្គាល់លក្ខណសម្បត្តិរបស់គ្រូពេទ្យចិនដោយពឹងផ្អែកលើបច្ចេកទេសសុខាភិបាលជំនាញរបស់ខ្លួន។

បន្ទាប់ពីនោះ លោកបានបង្កើតមន្ទីរពេទ្យហុនអិន ។ ជាធម្មតាមន្ទីរ-ពេទ្យរបស់លោកអាចទទួលបានអ្នកជំងឺ៥០នាក់មកព្យាបាលជំងឺជារៀងរាល់ថ្ងៃ ហើយគិតមកដល់ពេលនេះមន្ទីរ-ពេទ្យរបស់លោកបានជួយព្យាបាលជំងឺឱ្យអ្នកជំងឺនៅប្រទេសកម្ពុជាយ៉ាងតិច ៣ សែននាក់ហើយ ។

លោកធ្លាប់ទទួលអ្នកជំងឺបាក់ឆ្អឹងកម្នាក់ ។ អ្នកជំងឺនោះបានទៅមន្ទីរ-ពេទ្យច្រើន តែគ្មានមន្ទីរពេទ្យមួយណាអាចជួយគាត់បានទេ ។ គាត់ទៅសុំឱ្យលោកប្រធានឆឹនជួយ បន្ទាប់ពីព្យាបាលបានមួយខែ គាត់ជាសះស្បើយខ្លះ តែគ្មានសមត្ថភាពបង់ថ្លៃព្យាបាលជំងឺជិត ៥.០០០ដុល្លារអាមេរិកនោះ ។ លោកប្រធានឆឹន បានបញ្ចេញស្នាមញញឹម ហើយសម្រេចចិត្តជួយព្យាបាលជំងឺឱ្យគាត់ដោយមិនទារយកប្រាក់សោះ ។

នេះគឺជាលោក ឆឹន ស៊ីនហួ ដែលបាននិងកំពុងខិតខំជួយព្យាបាលជំងឺឱ្យបងប្អូនជនជាតិចិន និងជនជាតិខ្មែរនៅប្រទេសកម្ពុជា ។

គួរបញ្ជាក់ថា លោកកំពុងគិតគូរពិចារណាអំពីការបង្កើតមន្ទីរពេទ្យព្យាបាលជំងឺពកនៅប្រទេសកម្ពុជា ។

បច្ចុប្បន្ន លោកកំពុងខិតខំរកដៃគូសហប្រតិបត្តិការ ។ មន្ទីរពេទ្យនេះនឹងត្រូវបង្កើតឡើងក្នុងពេលឆាប់ៗនឹងអាចបំពេញចន្លោះក្នុងវិស័យសុខាភិបាលនៃប្រទេសកម្ពុជា ៕

## ខេត្តយូនណានទទួលភ្ញៀវទេសចរ២៦៨លាននាក់នៅឆមាសទី១នៃឆ្នាំ២០១៧

តាមការខុទ្ទេសនាមពីគណៈកម្មាធិការអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តយូនណាន បានឱ្យដឹងថា នៅឆមាសទី១ នៃឆ្នាំ២០១៧ ខេត្តយូនណានបានទទួលទេសចរជាតិ និងអន្តរជាតិ ២៦៨លាននាក់ កើនឡើង២៨,៧ភាគរយ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ ២០១៦ ហើយបានទទួលចំណូលសរុប ២៨៨.៣២០ លានយ័នប្រាក់ចិនពីវិស័យទេសចរណ៍ កើនឡើង៣១,៧ ភាគរយ ។ គួរបញ្ជាក់ថា បន្ទាប់ពីប្រកាស និងអនុវត្តន៍ "បទបញ្ជាអំពីវិធានការស្តីពីការគ្រប់គ្រងសណ្តាប់-ធ្នាប់ទីផ្សារទេសចរណ៍ខេត្តយូនណាន" សណ្តាប់ធ្នាប់ទីផ្សារទេសចរណ៍ខេត្តយូនណានបានត្រូវកែលម្អជាបន្ត-បន្ទាប់។

ខេត្តយូនណាន បានរៀបចំវគ្គបណ្តុះបណ្តាលនៅមូលដ្ឋានបណ្តុះបណ្តាលទេសចរចិន-អាស៊ាន ចំពោះមន្ត្រីទេសចរ និងអ្នកគ្រប់គ្រងសហគ្រាសទេសចរណ៍ចំនួន១២០រូប



ខណៈដែលផ្លូវដែកល្បឿន លឿនបានបើកធ្វើចរាចរកាលពីឆ្នាំទៅ ខេត្តយូនណាន បានទទួលកំណើនភ្ញៀវទេសចរដែលធ្វើដំណើរតាមរថភ្លើងល្បឿនលឿនមកពីខេត្តផ្សេងៗ ។ នេះគឺជាក្បាលរថភ្លើងចូលស្ថានីយរថភ្លើងល្បឿនលឿនគុនមីងណាន (រូបថត ដោយ Li Qiuming )

ដែលមកពីប្រទេសមីយ៉ាន់ម៉ា និងកម្ពុជាជាដើម ដើម្បីជំរុញការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការ ។ ជាពិសេសស្រុកតឺហុងនៃខេត្តយូនណានបានសាកល្បងដាក់ចេញនូវគោលនយោបាយថ្មីអំពីការទាក់ទាញទេសចរអន្តរជាតិ ដែលមកពីប្រទេសផ្សេងៗ និងទាក់ទាញទេសចរអន្តរជាតិ ដែលទៅដើរលេងប្រទេសមីយ៉ាន់ម៉ាឱ្យមកធ្វើទេសចរណ៍នៅស្រុកតឺហុង។ ស្រុកស៊ីសាំងប៉ាន់ណាបានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយស្ថាប័នទេសចរណ៍នៃប្រទេសថៃ ឡាវ និងមីយ៉ាន់ម៉ា ដើម្បីរួមគ្នាអភិវឌ្ឍន៍ខ្សែផ្លូវទេសចរណ៍ថ្មី ។ ស្រុកហុងហឺ និងវិនសានកំពុងខិតខំបង្កើនកិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយខេត្តក្រុងផ្សេងៗនៅភាគខាងជើងនៃប្រទេសវៀតណាម ដើម្បីបង្កើតខ្សែផ្លូវទេសចរណ៍អន្តរជាតិថ្មី ដែលមានលក្ខណៈល្អប្រណីត និងពោរពេញទៅដោយកម្លាំងទាក់ទាញ ៕

## ពាណិជ្ជកម្មផ្សិតព្រៃនៅស្រុកណានហួ ឈានដល់កម្រិតកំពូល



អ្នកលក់កំពុងតែបង្ហាញ កញ្ចែងផ្សិតព្រៃនៅខាងមុខកាមេរ៉ានៅផ្សារផ្សិតព្រៃ ស្រុកណានហួ (រូបថត ដោយ Yang Zheng )

***ដោយ យ៉ាង ជឹង***

ប៉ុន្មានថ្ងៃនេះ ពាណិជ្ជកម្មផ្សិតព្រៃនៅផ្សារស្រុកណានហួ បានឈានដល់កម្រិតកំពូល ដោយបានសម្រេចទំហំពាណិជ្ជកម្មផ្សិតព្រៃជិត ២០០ តោនក្នុងមួយថ្ងៃ ដែលមានតម្លៃស្មើនឹងជាង ១០ លានយ័នប្រាក់ចិន ។

ប៉ុន្មានឆ្នាំមកនេះ សាលារដ្ឋបាលស្រុកណានហួ បានអនុវត្តន៍ផែនការ "បណ្តុះផ្សិតដោយហាមចូលតំបន់ភ្នំ" ដែលបានថែរក្សាដោយមានប្រសិទ្ធភាពខ្ពស់នូវអេកូ-បរិស្ថានរបស់ផ្សិតព្រៃ ។ គួរបញ្ជាក់ថា តំបន់ភ្នំ "ហាមចូល" មានផ្ទៃក្រឡាជាង ១៣ ហិកតាស្មើនឹង ៨០ ភាគរយនៃទំហំព្រៃឈើនៅស្រុកណានហួទាំងមូល ហើយអាចប្រមូលបានផ្សិតព្រៃមួយម៉ឺនតោនក្នុងមួយឆ្នាំ ។ ពាណិជ្ជកម្មផ្សិតព្រៃនៅស្រុកណានហួ មានទំហំសរុបជិត៧.០០០ពាន់តោន ដែលមានតម្លៃជាង៤០០លានយ័ន ៕

## មាន់ព្រៃរងាវក្នុងតំបន់ភ្នំ

***ដោយ ចាំង វិន (ដកស្រង់ចេញពី "កាសែតប្រជាជន ដេលី")***

អ្នករៀបរៀង: ពេលនេះយើងខ្ញុំសូមបន្តនិទាន "រឿងចិន" ជូនលោកអ្នកដើម្បីខុទ្ទេសនាមអំពីកំណែទម្រង់ផ្នែកផ្គត់ផ្គង់របស់ប្រទេសចិន ។ សូមខុទ្ទេស-នាមអំពីជីវប្រវត្តិរបស់លោក ជាំង ឆាវឈួន ដែលជាអ្នកចិញ្ចឹមមាន់ម្នាក់នៅស្រុកណានជាំង ខេត្តស៊ីឈួន ប្រទេសចិន ។ លោកពេញចិត្តចំពោះជម្រើសរបស់ខ្លួន ពីព្រោះកាលពីមុនលោកធ្លាប់ជួបនឹងការលំបាកស្ទើរនឹងក្ស័យធន តែឥឡូវបែរជាអាចបានចំណេញជាងមួយសែនយ៉ាន់ ជារៀងរាល់ឆ្នាំ ។

សព្វថ្ងៃ ទោះបីជានៅកន្លែងណាក៏ដោយ លោក ជាំង ឆាវឈួន ត្រូវតែយកPOWER BANK ពីរនៅតាមខ្លួន ។ លោកបញ្ជាក់ថា អ្នកវាយទូរស័ព្ទឱ្យខ្ញុំច្រើនពេក ។ ពួកគេចង់ទិញសត្វមាន់របស់ខ្ញុំ ហើយមានថៅកែភោជ-នីយដ្ឋានច្រើនម្តងក៏ទិញមាន់របស់ខ្ញុំរាប់សិបក្បាល ។ ចំពោះអតិថិជនដែលទិញមាន់ពីខ្ញុំជាលើកទី ១ ខ្ញុំតែងតែផ្ញើរូបថត និងវីដេអូរបស់មាន់ព្រៃដែលខ្ញុំចិញ្ចឹមតាមរបៀបធម្មជាតិឱ្យពួកគេដើម្បីធ្វើឱ្យគេទុកចិត្ត ។

លោកធ្លាប់រៀនមុខវិជ្ជាចិញ្ចឹមសត្វនៅសាកលវិទ្យាល័យ ។ ក្រោយពីបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យនៅឆ្នាំ២០១១ លោកបានបង្កើតកសិដ្ឋានចិញ្ចឹមសត្វមាន់របស់ខ្លួន ។ ពេលដំបូងលោកគិតថា មាន់ធម្មតាសម្រាប់ស៊ីសាច់អាចលូតលាស់បានឆាប់ជាពិសេសវាស៊ីចំណីធម្មតា ហើយអាចយកទៅលក់តាមទីផ្សារដោយចិញ្ចឹមបានតែ២ខែប៉ុណ្ណោះ ដូច្នេះបើចិញ្ចឹមមាន់ប្រភេទនេះ មុខជានឹងអាចបានចំណេញច្រើន ។ ប៉ុន្តែគ្មានអ្នកណាចង់ទិញមាន់ពីលោកទេ ហើយបានធ្វើឱ្យលោកមិនអាចបានចំណេញសោះ បែរជាខាតដើមច្រើន ។ លោកចិញ្ចឹមមាន់ធម្មតាសម្រាប់ស៊ីសាច់បានពីរឆ្នាំ ស្ទើរនឹងក្ស័យធនតែម្តង ។

នៅពេលនោះ មានអ្នកជំនាញការ ២-៣ រូប ដែលមកពីមន្ទីរកសិកម្មស្រុកណានជាំង ទៅសិក្សាស្រាវជ្រាវអំពីធនធានអេកូ-ធម្មជាតិនៅភូមិរបស់លោក ហើយស្នើឱ្យលោកចិញ្ចឹមមាន់ព្រៃពូជ "ប៉ាសាន" ដែលជាមាន់ព្រៃពិសេសមួយប្រភេទនៅស្រុកនោះ ។ មាន់ប្រភេទនេះត្រូវចិញ្ចឹមតាមរបៀបធម្មជាតិ ។ វាស៊ីស្មៅ ដង្កូវ និងធញ្ញជាតិជាដើម ហើយអាចលក់តាមទីផ្សារក្នុងតម្លៃខ្ពស់ និងអាចទទួលបានការពេញនិយមពីអតិថិជន ។ ប៉ុន្តែវាលូតលាស់បានយឺត ដែលត្រូវតែចិញ្ចឹមជាង៧ ខែទើបអាចយកទៅលក់តាមទីផ្សារបាន ។

សំណើនេះ បានធ្វើឱ្យលោកសប្បាយយ៉ាងខ្លាំង ។ លោកបានប្រាប់អ្នកកាសែតថា ខ្ញុំបានយកលុយសល់បន្តិចបន្តួចទៅទិញកូនមាន់ព្រៃ "ប៉ាសាន" នេះជាង៥០០ក្បាល ។ ខ្ញុំខិតខំចិញ្ចឹមបានកន្លះឆ្នាំ ពិតជាពិបាកមែន ។ តែនៅពេលយកទៅលក់តាមទីផ្សារ ខ្ញុំសប្បាយណាស់ ពីព្រោះមាន់ប្រភេទនេះបានទទួលការពេញនិយមពីអតិថិជន ។ ក្នុងរយៈពេលមិនដល់កន្លះខែខ្ញុំបានលក់អស់ក្នុងតម្លៃជាង៦០យ័ន/គីឡូក្រាម ដែលបានធ្វើឱ្យខ្ញុំចំណេញ ច្រើន ។

បច្ចុប្បន្ន កសិដ្ឋានចិញ្ចឹមមាន់ព្រៃរបស់លោកអាចផ្តល់ដល់អ្នកចិញ្ចឹមមាន់ព្រៃជាង៥០នាក់នូវកូនមាន់ជាងមួយម៉ឺនក្បាលជារៀងរាល់ឆ្នាំ ដែលអាចធ្វើឱ្យលោកទទួលបានចំណេញជាង ១០ ម៉ឺនយ័ន ៕